ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ២៣០៩ ព.ណ ន.អវឯទ

ថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦

សេចក្តីជូនដំណឹង

ស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយប្រចាំសប្តាហ៍ចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦

- យោងប្រកាសអន្តរក្រសួងលេខ០០៨៣ ពណ. អវឯ.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់និងអន្តរជាតិ

រាជរដ្ឋាភិបាលបាន ១. បន្តបញ្ចុះចំនួន ៦,៥សេនដុល្លារ/លីត្រ ក្នុងគោលបំណងជួយសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋ ២. បន្តបញ្ចុះ ១សេនដុល្លារ/លីត្របន្ថែមទៀត ដោយសារថ្លៃប្រេងសាំងអន្តរជាតិឡើងលើសពី ៩០ដុល្លារ/បារ៉ែល និងប្រេងម៉ាស៊ូតអន្តរជាតិឡើងលើស ១០០ដុល្លារ/បារ៉ែល ៣. ពន្ធគយ ០ (សូន្យ) ដុល្លារ និង ៤. ផ្អែកតាមសភាពការណ៍ និងថ្លៃប្រេងឥន្ធនៈបន្តកើនឡើងនៅទីផ្សារអន្តរជាតិ ក៏ដូចជាថ្លៃដឹកជញ្ជូននិងថ្លៃធានារ៉ាប់រងមានការកើនឡើងខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី បានសម្រេច បញ្ចុះអាករបន្ថែមលើប្រេងសាំង និងប្រេងម៉ាស៊ូតមក ០ (សូន្យ) ដុល្លារ, បញ្ចុះអាករពិសេសលើប្រេងសាំងពី ៣០% មក ១៥% និងប្រេងម៉ាស៊ូត ពី ៤% មក ០% និង បញ្ចុះអាករលើតម្លៃបន្ថែមលើប្រេងសាំងពី ១០% មក ៤% និងប្រេងម៉ាស៊ូត ពី ១០% មក ០% ដោយរាជរដ្ឋាភិបាលទទួលបន្ទុកជំនួសសរុបចំនួន ៦% សម្រាប់ប្រេងសាំង និង ១០% សម្រាប់ប្រេងម៉ាស៊ូត។**

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈត្រូវអនុវត្តជារៀងរាល់សប្តាហ៍ចាប់ពីវេលាម៉ោង ១ រសៀលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦ រហូតដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៦ គឺត្រូវលក់ ៤ ០៥០រៀល/លីត្រ សម្រាប់ប្រេងសាំងធម្មតា (Gasoline 92) និង ៤ ០០០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត (Gasoil 10ppm)។

តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា

ល.រ	អធិប្បាយ	ប្រេងសាំងធម្មតា/លីត្រ Gasoline 92	ប្រេងម៉ាស៊ូត/លីត្រ Gasoil 10ppm
១	ថ្លៃប្រេងអន្តរជាតិជាមធ្យម (Average MOPS)	០,៦២៣៥ ដុល្លារ	០,៧០៥០ ដុល្លារ
២	ពន្ធ៖	០,០៧៨៥ ដុល្លារ	០,០០០០ ដុល្លារ
	ពន្ធគយ	០,០០០០ ដុល្លារ	០,០០០០ ដុល្លារ
	អាករបន្ថែម	០,០០០០ ដុល្លារ	០,០០០០ ដុល្លារ
	អាករពិសេស (ប្រេងសាំងបញ្ចុះពី ៣០% មក ១៥% និងប្រេងម៉ាស៊ូតបញ្ចុះពី ៤% មក ០%)	០,០៧៨៥ ដុល្លារ	០,០០០០ ដុល្លារ
៣	បុព្វលាភ (Premium)	០,២០ ដុល្លារ	០,២៣ ដុល្លារ
៤	អាករលើតម្លៃបន្ថែម (ប្រេងសាំងបញ្ចុះពី ១០% មក ៤% និងប្រេងម៉ាស៊ូតបញ្ចុះពី ១០% មក ០%)	០,០៣៦១ ដុល្លារ	០,០០០០ ដុល្លារ
៥	ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ)	០,៩៣៨១ ដុល្លារ	០,៩៣៥០ ដុល្លារ
៦	ថ្លៃធានានិរន្តរភាពនៃការផ្គត់ផ្គង់ (ដោយគិតបញ្ចូលទាំងថ្លៃដឹកជញ្ជូន និងសោធានារ៉ាប់រងដែលក្រុមហ៊ុនត្រូវទទួលបន្ទុក)	០,០៧១៥ ដុល្លារ	០,០៦៥០ ដុល្លារ
៧	ក្រុមហ៊ុនប្រេងឥន្ធនៈបញ្ចុះតម្លៃ	០,០១ ដុល្លារ	០,០១ ដុល្លារ
៨	ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ)	១,០០ ដុល្លារ	០,៩៩ ដុល្លារ
៩	ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល)	៤ ០៥០ រៀល	៤ ០០០ រៀល

សម្គាល់៖ - ថ្លៃប្រេងឥន្ធនៈមុនការបញ្ចុះអាករបន្ថែម, អាករពិសេស និងអាករលើតម្លៃបន្ថែម៖ **ប្រេងសាំង ៤ ៤០០រៀល/លីត្រ និងប្រេងម៉ាស៊ូត ៤ ៤០០រៀល/លីត្រ**។
- អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦ ដែលស្មើនឹង ៤ ០២៦រៀល/ដុល្លារអាមេរិក។
- ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាដែលបានគណនា និងបង្ហាញខាងលើ គឺផ្អែកលើតម្លៃប្រេងឥន្ធនៈដែលបានប្រែប្រួលនៅលើទីផ្សារអន្តរជាតិ ស្របតាមក្របខ័ណ្ឌសូមដូចបានយោងខាងដើម។ បណ្តាស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជា អាចលក់ប្រេងក្នុងតម្លៃណាមួយ ដែលទាបជាងថ្លៃដែលបានគណនាខាងលើ តាមការប្រកួតប្រជែងជាក់ស្តែងនៃទីផ្សារនៅកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបថាថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ នឹងត្រូវដាក់ឱ្យប្រើជារៀងរាល់ **ថ្ងៃអង្គារ វេលាម៉ោង ១ រសៀល** និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិឱ្យបានគត់មត់តាមសេចក្តីជូនដំណឹងនេះ។